សន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំង

# ថ្នាំវ៉ាក់សាំងជំងឺអុតស្វាយ

## *អ្វីដែលអ្នកត្រូវដឹង*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំងជាច្រើនមានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ សូមចូលទៅ www.immunize.org/vis

## 1 ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

ជំងឺអុតស្វាយគឺជាជំងឺកុមារដែលកើតជាទូទៅ។ ជាធម្មតា ជំងឺនេះគឺជាជំងឺស្រាល ប៉ុន្តែវាអាចជាជំងឺធ្ងន់ធ្ងរ ជាពិសេសចំពោះទារក និងមនុស្សពេញវ័យ។

- ជំងឺនេះបង្ករោគកន្ទួល រមាស់ គ្រុនក្តៅ និងនឿយហត់។
- ជំងឺនេះអាចបណ្តាលឲ្យកើតរោគស្បែកធ្ងន់ធ្ងរ មានស្លាកស្នាម កើតជំងឺហើមសួត ខូចខួរក្បាល ឬស្លាប់បាត់បង់ជីវិត។
- មេរោគជំងឺអុតស្វាយអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមខ្យល់ ឬដោយប៉ះពាល់វត្ថុរាវចេញពីពងទឹកជំងឺអុតស្វាយ។
- អ្នកដែលធ្លាប់កើតជំងឺអុតស្វាយ អាចកើតរោគកន្ទួលដែលឈឺចុកចាប់ ដែលគេហៅថាជំងឺរើម រយៈពេលច្រើនឆ្នាំក្រោយមក។
- នៅសហរដ្ឋអាមេរិក មុនពេលមានថ្នាំវ៉ាក់សាំងនេះ មនុស្សប្រហែល 11,000 នាក់ បានដេកសម្រាកព្យាបាលជំងឺអុតស្វាយនៅមន្ទីរពេទ្យ រៀងរាល់ឆ្នាំ។
- នៅសហរដ្ឋអាមេរិក មុនពេលមានថ្នាំវ៉ាកសាំងនេះ មនុស្សប្រហែល 100 នាក់បានស្លាប់បាត់បង់ជីវិតរៀងរាល់ឆ្នាំដោយសារជំងឺអុតស្វាយ។

ថ្នាំវ៉ាក់សាំងជំងឺអុតស្វាយអាចបង្ការជំងឺអុតស្វាយបាន។

មនុស្សភាគច្រើន ដែលបានចាក់ថ្នាំវ៉ាក់សាំងជំងឺអុតស្វាយ នឹងមិនកើតជំងឺអុតស្វាយទេ។ ប៉ុន្តែ ប្រសិនបើអ្នកដែលបានចាក់ថ្នាំវ៉ាក់សាំងរួចកើតជំងឺអុតស្វាយនោះ ជាធម្មតា ជំងឺអុតស្វាយមានកម្រិតស្រាលណាស់។ ពួកគេនឹងមានពងទឹកចំនួនតិចតួច មិនសូវក្តៅខ្លួនទេ ហើយនឹងជាសះស្បើយយ៉ាងឆាប់រហ័ស។

## 2 តើអ្នកណាគួរចាក់ថ្នាំវ៉ាក់សាំងជំងឺអុតស្វាយ ហើយនៅពេលណា?

**ការទទួលវ៉ាក់សាំងជាទម្លាប់**

កុមារដែលមិនធ្លាប់មានជំងឺអុតស្វាយ គួរទទួលថ្នាំវ៉ាក់សាំងចំនួន 2 ដូស នៅអាយុ៖

| | |
|---|---|
| ដូសទី 1៖ | អាយុ 12–15 ខែ |
| ដូសទី 2៖ | អាយុ 4–6 ឆ្នាំ (អាចចាក់ឆាប់ជាងនេះ បើយ៉ាងហោចណាស់ 3 ខែ បន្ទាប់ពីដូសទី 1) |

មនុស្សអាយុ 13 ឆ្នាំ និងច្រើនជាងនេះ (ដែលដែលមិនធ្លាប់មានជំងឺអុតស្វាយ ឬទទួលថ្នាំវ៉ាក់សាំងជំងឺអុតស្វាយ) គួរទទួលថ្នាំវ៉ាក់សាំងចំនួនពីរដូស រយៈពេលយ៉ាងហោចណាស់ 28 ថ្ងៃដាច់ពីគ្នា។

**ការទទួលវ៉ាក់សាំងឲ្យទាន់ពេល**

អ្នកណាដែលមិនបានចាក់ថ្នាំវ៉ាក់សាំងពេញលេញ ហើយមិនធ្លាប់កើតជំងឺអុតស្វាយ គួរទទួលថ្នាំវ៉ាក់សាំងជំងឺអុតស្វាយ 1 ឬ 2 ដូស។ ការកំណត់ពេលចាក់ថ្នាំវ៉ាក់សាំងដូសទាំងនេះ អាស្រ័យទៅលើអាយុ។ សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នក។

ថ្នាំវ៉ាក់សាំងជំងឺអុតស្វាយអាចចាក់ក្នុងពេលដំណាលគ្នានឹងថ្នាំវ៉ាក់សាំងដទៃទៀត។

សម្គាល់៖ ថ្នាំវ៉ាក់សាំងរួមផ្សំមួយ ហៅថា ថ្នាំវ៉ាក់សាំង **MMRV** ដែលមានទាំងថ្នាំវ៉ាក់សាំងជំងឺអុតស្វាយ និងថ្នាំវ៉ាក់សាំង MMR (ថ្នាំវ៉ាក់សាំងកញ្ជ្រឹល ក្រឡទែន និងកញ្ជ្រឹលស្រាល) និងអាចចាក់ជាថ្នាំវ៉ាក់សាំងមួយជំនួសថ្នាំវ៉ាក់សាំងពីរចំពោះអ្នកមានអាយុ 12 ឆ្នាំ និងក្រោម 12 ឆ្នាំ។

## 3 មនុស្សមួយចំនួនមិនគួរចាក់វ៉ាក់សាំងជំងឺអុតស្វាយទេ ឬគួររង់ចាំ។

- គេមិនគួរចាក់ថ្នាំវ៉ាក់សាំងជំងឺអុតស្វាយឡើយ ប្រសិនបើគេធ្លាប់មានប្រតិកម្មអាឡាក់ស៊ីដែលគំរាមដល់អាយុជីវិតទៅនឹងថ្នាំវ៉ាក់សាំងជំងឺអុតស្វាយដូសមុន ឬទៅនឹងជាតិអន្ទិល (gelatin) ឬថ្នាំផ្សះ neomycin។
- ជាធម្មតា អ្នកដែលមានជំងឺធ្ងន់ល្មម ឬធ្ងន់ធ្ងរ នៅពេលត្រូវដាក់ថ្នាំវ៉ាក់សាំង គួររង់ចាំរហូតទាល់តែពួកគេជាសះស្បើយសិន មុនពេលទទួលថ្នាំវ៉ាក់សាំងជំងឺអុតស្វាយ។
- ស្ត្រីមានផ្ទៃពោះគួររង់ចាំសម្រាលកូនរួចសិនទើបចាក់ថ្នាំវ៉ាក់សាំងជំងឺអុតស្វាយបាន។ ស្ត្រីមិនគួរមានផ្ទៃពោះរយៈពេល 1 ខែ បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងជំងឺអុតស្វាយ។
- មនុស្សមួយចំនួនគួរឆែកជាមួយនឹងវេជ្ជបណ្ឌិតរបស់ខ្លួនអំពីថាតើ ពួកគេគួរទទួលថ្នាំវ៉ាក់សាំងជំងឺអុតសាយ ឬយ៉ាងណា ហើយមនុស្សទាំងនោះរួមបញ្ចូលអ្នក៖
  - មានមេរោគអេដស៍/ជំងឺអេដស៍ ឬជំងឺផ្សេងទៀតដែលប៉ះពាល់ដល់ប្រព័ន្ធស៊ាំ
  - កំពុងទទួលការព្យាបាលដោយប្រើប្រាស់ថ្នាំដែលប៉ះពាល់ដល់ប្រព័ន្ធស៊ាំ ដូចជាថ្នាំ steroids សម្រាប់រយៈពេល 2 សប្តាហ៍ ឬយូរជាងនេះ
  - មានជំងឺមហារីក
  - កំពុងទទួលការព្យាបាលជំងឺមហារីកដោយប្រើកាំរស្មី ឬឱសថ
- មនុស្សដែលទើបតែបញ្ចូលឈាមថ្មីៗ ឬទទួលបានផលិតផលឈាមដទៃទៀត គួរសួរវេជ្ជបណ្ឌិតរបស់ខ្លួនថាតើ ពេលណាពួកគេអាចទទួលថ្នាំវ៉ាក់សាំងជំងឺអុតស្វាយបាន។

សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នកសម្រាប់ព័ត៌មានបន្ថែម។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 4 តើមានហានិភ័យអ្វីខ្លះដោយសារថ្នាំវ៉ាក់សាំងជំងឺអុតស្វាយ?

ថ្នាំវ៉ាក់សាំង គឺដូចឱសថផងដែរ គឺអាចបង្កបញ្ហាធ្ងន់ធ្ងរ ដូចជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ។ និភ័យដែលថ្នាំវ៉ាកសាំងជំងឺអុតស្វាយបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតនោះ គឺមានកម្រិតតិចតួចបំផុត។

ការទទួលថ្នាំវ៉ាក់សាំងជំងឺអុតស្វាយគឺមានសុវត្ថិភាពច្រើនជាងការឆ្លងជំងឺអុតស្វាយ។ មនុស្សភាគច្រើន ដែលទទួលថ្នាំវ៉ាក់សាំងជំងឺអុតស្វាយ ពុំមានបញ្ហាជាមួយនឹងថ្នាំវ៉ាក់សាំងទេ។ ជាធម្មតា ប្រតិកម្មអាឡាក់ស៊ីអាចកើតឡើងញឹកញាប់បន្ទាប់ពីដូសទី 1 ជាងដូសទី 2។

### បញ្ហាស្រាល

- ដំបៅ ឬហើមនៅត្រង់កន្លែងចាក់ថ្នាំវ៉ាក់សាំង (កុមារប្រហែលម្នាក់ក្នុងចំណោម 5 នាក់ និងម្នាក់ក្នុងចំណោមយុវជន និងមនុស្សពេញវ័យ 3 នាក់)
- គ្រុនក្តៅ (មនុស្សម្នាក់ក្នុងចំណោម 10 នាក់ ឬទាបជាងនេះ)
- កន្ទួលស្រាលរយៈពេលរហូតដល់ទៅ 1 ខែបន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងនេះ (មនុស្សម្នាក់ក្នុងចំណោម 25 នាក់)។ មនុស្សទាំងនេះអាចចម្លងជំងឺទៅសមាជិកដទៃទៀតក្នុងគ្រួសារ ប៉ុន្តែករណីនេះគឺកម្រណាស់។

### បញ្ហាធ្ងន់ល្មម

- ប្រកាច់ (កន្ត្រាក់ ឬឈរភ្នែក) ដែលបង្កដោយគ្រុនក្តៅ (កម្រណាស់)។

### បញ្ហាធ្ងន់ធ្ងរ

- ជំងឺហើមសួត (កម្រណាស់)

បញ្ហាធ្ងន់ធ្ងរដទៃទៀត ដែលរួមបញ្ចូលប្រតិកម្មខួរក្បាលធ្ងន់ធ្ងរ និងចំនួនកោសិកាឈាមទាប ត្រូវបានរាយការណ៍ បន្ទាប់ពីចាក់វ៉ាក់សាំងជំងឺអុតស្វាយ។ បញ្ហាទាំងនេះគឺកម្រកើតឡើងណាស់ ដូច្នេះអ្នកជំនាញមិនអាចកំណត់ថា បញ្ហាទាំងនេះបង្កឡើងដោយថ្នាំវ៉ាក់សាំង ឬយ៉ាងណាទេ។ ប្រសិនបើមែន វាកម្រកើតណាស់។

> សម្គាល់៖ ដូសទី 1 នៃថ្នាំវ៉ាក់សាំង **MMRV** ជាប់ពាក់ព័ន្ធនឹងរោគកន្ទួល ហើយមានអត្រាគ្រុនក្តៅខ្ពស់ជាងការចាក់ថ្នាំវ៉ាក់សាំង MMR និងថ្នាំវ៉ាក់សាំងជំងឺអុតស្វាយដាច់ដោយឡែកពីគ្នា។ រោគកន្ទួលត្រូវបានរាយការណ៍ថាកើតឡើងចំពោះមនុស្សប្រហែលម្នាក់ក្នុងចំណោម 20 នាក់ ហើយគ្រុនក្តៅត្រូវបានរាយការណ៍ការណ៍ថាកើតឡើងចំពោះមនុស្សម្នាក់ក្នុងចំណោម 5 នាក់។
>
> រោគប្រកាច់ ដែលបង្កឡើងដោយគ្រុនក្តៅ ក៏ត្រូវបានរាយការណ៍ថាកើតឡើងញឹកញាប់ផងដែរ បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង MMRV។ ជាធម្មតា បញ្ហាទាំងនេះកើតឡើង 5–12 ថ្ងៃបន្ទាប់ពីចាក់ដូសទី 1។

## 5 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរ?

### តើខ្ញុំគួរប្រយ័ត្នចំពោះអ្វីខ្លះ?

- សូមប្រយ័ត្នចំពោះអ្វីដែលធ្វើឲ្យលោកអ្នកព្រួយបារម្ភ ដូចជាសញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬការប្តូរឥរិយាបថ។

  សញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ អាចរួមបញ្ចូលកន្ទួល ហើមមុខនិងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងចុះខ្សោយ។ បញ្ហាទាំងនេះនឹងចាប់ផ្តើមកើតឡើងរយៈពេលប៉ុន្មាននាទីទៅប៉ុន្មានម៉ោងប៉ុណ្ណោះ បន្ទាប់ពីការចាក់ថ្នាំវ៉ាក់សាំង។

### តើខ្ញុំគួរធ្វើអ្វីខ្លះ?

- ប្រសិនបើលោកអ្នកគិតថា វាគឺជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ឬស្ថានការណ៍សង្គ្រោះបន្ទាន់ដទៃទៀតដែលមិនអាចរង់ចាំបាន សូមទូរស័ព្ទទៅ 9-1-1 ឬយកអ្នកជំងឺទៅកាន់មន្ទីរពេទ្យដែលជិតបំផុត។ បើមិនអញ្ចឹងទេ សូមទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់លោកអ្នក។
- បន្ទាប់មក ប្រតិកម្មគួររាយការណ៍ទៅប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាកសាំង (Vaccine Adverse Event Reporting System (VAERS))។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចដាក់បញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចរាយការណ៍ដោយផ្ទាល់តាមរយៈវេបសាយ VAERS នៅ **www.vaers.hhs.gov** ឬតាមរយៈហៅទូរស័ព្ទមក **1-800-822-7967**។

*VAERS គឺសម្រាប់តែការរាយការណ៍ប្រតិកម្មផ្សេងៗប៉ុណ្ណោះ។ ប្រព័ន្ធនេះពុំផ្តល់ដំបូន្មានវេជ្ជសាស្ត្រទេ។*

## 6 កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (National Vaccine Injury Compensation Program)

កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (National Vaccine Injury Compensation Program (VICP)) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។

បុគ្គលដែលជឿជាក់ថា ខ្លួនអាចធ្លាប់រងរបួសដោយសារថ្នាំវ៉ាក់សាំងមួយ អាចធ្វើការសិក្សាអំពីកម្មវិធី និងអំពីការដាក់ពាក្យទាមទារសំណង ដោយទូរស័ព្ទមក**1-800-338-2382** ឬចូលទៅវេបសាយ VICP នៅ **www.hrsa.gov/vaccinecompensation**។

## 7 តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នក។ 1-888-767-4687
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- ទាក់ទងមជ្ឈមណ្ឌលទប់ស្កាត់ និង បង្ការជំងឺឆ្លង (CDC):
  - ទូរស័ព្ទមកលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលទៅវេបសាយ CDC នៅ **www.cdc.gov/vaccines**

DCH-0451CA
AUTH: P. H. S., Act 42, Sect. 2126.

Translation provided by the Immunization Action Coalition

Vaccine Information Statement (Interim)

# Varicella Vaccine

3/13/2008 Khmer

Office Use Only

42 U.S.C. § 300aa-26

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវពត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណគ្រឹមត្រូវ. ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត. ពត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនពត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។